អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២១

# សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិ

សហព្រះរាជអាជ្ញាអន្តរជាតិ (“ស.ព.អ”) ចេញសេចក្តីប្រកាសព័ត៌មាននេះ ដើម្បីបំភ្លឺអំពីគោលជំហររបស់ខ្លួនទាក់ទងនឹងការយល់ច្រឡំដែលអាចកើតមានអំពីស្ថានភាពរបស់តុលាការនៅលើករណីរឿងក្តីនានាដែលមិនទាន់បានដោះស្រាយចប់សព្វគ្រប់នៅ អ.វ.ត.ក ដែលកើតចេញពីការផ្សាយមិនបានពេញលេញរបស់វិទ្យុសំឡេង អាមេរិកាំង (Voice of America) ជាភាសាខ្មែរនាពេលថ្មីៗនេះ ដែលបានធ្វើឡើងតាមរយៈសេចក្តីថ្លែងការណ៍របស់អ្នកនាំពាក្យនៃកិច្ចការទំនាក់ទំនងសាធារណៈរបស់រដ្ឋបាលតុលាការ។

នៅក្នុងការផ្សាយនោះ អ្នកនាំពាក្យ អ.វ.ត.ក ត្រូវបានគេរាយការណ៍ថាបានថ្លែងថា នៅក្នុងពេលនេះ តុលាការនឹងត្រូវបញ្ចប់លើបញ្ហាច្បាប់ និងរឿងក្តីនានាដែលនៅសល់ដែលនឹងមិនដំណើរការ។ “យើងនៅមានកិច្ចការរដ្ឋបាលខ្លះដែលត្រូវធ្វើបញ្ចប់រវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ នៅមុនពេលសាលាក្តីនេះនឹងត្រូវបិទបញ្ចប់។ វាមានន័យថា បញ្ចប់បេសកកម្មរបស់ខ្លួន”។

ស.ព.អ យល់ថា សេចក្តីថ្លែងការណ៍របស់អ្នកនាំពាក្យមិនត្រូវបានគេរាយការណ៍នូវខ្លឹមសារទាំងស្រុងរបស់វាទេ ហើយអ្នកនាំពាក្យបានចង្អុលបង្ហាញថា មានករណីរឿងក្តីនានានៅចំពោះមុខតុលាការនេះដែលត្រូវធ្វើការសម្រេចតាមផ្លូវតុលាការ បន្ថែមទៅលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ ទាក់ទងនឹង ខៀវ សំផន។

ស.ព.អ សូមបញ្ជាក់អះអាងថា ពិតជាមានករណីរឿងក្តីនានានៅចំពោះមុខ អ.វ.ត.ក ដែលត្រូវធ្វើការសម្រេចតាមផ្លូវតុលាការមែន មុនពេលដែលតុលាការនេះអាចបញ្ចប់កិច្ចការរបស់ខ្លួន។ បន្ថែមទៅលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២, សំណុំរឿង ០០៣ និងសំណុំរឿង ០០៤ បច្ចុប្បន្នកំពុងស្ថិតនៅក្នុងដំណាក់កាលមុនការជំនុំជម្រះនៅឡើយ។ រឿងក្តីទាំងនេះពាក់ព័ន្ធនឹងការចោទប្រកាន់ប្រឆាំងនឹងជនត្រូវចោទពីរនាក់ ចំពោះឧក្រិដ្ឋកម្មនៃអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ដែលបានប្រព្រឹត្តប្រឆាំងនឹងបុគ្គលរាប់ម៉ឺននាក់ដែលត្រូវបានគេសម្លាប់ និង/ឬ រំលោភបំពានជាប្រព័ន្ធ នៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។ រឿងក្តីទាំងពីរកំពុងតែរង់ចាំសេចក្តីសម្រេចពីអង្គបុរេជំនុំជម្រះ។ ដូច្នេះ មិនទាន់មានការសម្រេចតាមផ្លូវតុលាការជាស្ថាពរណាមួយអំពីថាតើ រឿងក្តីទាំងនេះនឹងត្រូវធ្វើដំណើរទៅជំនុំជម្រះដែរឬអត់នៅឡើយទេ។

ហេតុដូច្នេះ ជាគោលជំហររបស់ ស.ព.អ គឺថា អាណត្តិតាមផ្លូវតុលាការរបស់ អ.វ.ត.ក នឹងមិនទាន់បញ្ចប់ឡើយ បើសិនសាលដីកានៃបណ្តឹងសាទុក្ខសំណុំរឿង ០០២/០២ មិនទាន់បានចេញ ហើយសំណុំរឿង ០០៣ និង សំណុំរឿង ០០៤ មិនត្រូវបានសម្រេចតាមផ្លូវតុលាការ (ខុសពីតាមផ្លូវរដ្ឋបាល) ទោះជាតាមរយៈការជំនុំជម្រះ និងបណ្តឹងឧទ្ធរណ៍/បណ្តឹងសាទុក្ខឬតាមរបៀបណាផ្សេងក៏ដោយ។ សេចក្តីរាយការណ៍ណាក៏ដោយដែលបង្កប់ន័យថា ចៅក្រមបានសម្រេចជាផ្លូវការណ៍លើសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ គឺជាការបន្ទាបតម្លៃ និងមើលស្រាលចំពោះសុចរិតភាពរបស់តុលាការនេះ និងចៅក្រមរបស់ អ.វ.ត.ក ដែលពួកគាត់ត្រូវបានសន្មត់ថា បំពេញកិច្ចដោយឯករាជ្យ និងមិនលម្អៀងនៅក្នុងក្របខណ្ឌតុលាការនៃ អ.វ.ត.ក៕